ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២៤៤៧ ......សហវ.......

រាជធានីភ្នំពេញថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៧

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**កម្មវត្ថុ:** ករណីសំណើសុំចុះកិច្ចសន្យាជាមួយក្រុមហ៊ុន **ម៉ែន សារុន អាហ័រណនីហ័រណ និងសំណង់** ស្តីពីការផ្គត់ផ្គង់អង្ករបបកងទ័ពសម្រាប់ឆ្នាំ២០១៧ ជូនក្រសួងការពារជាតិ ។

**យោង** : -លិខិតលេខ ១១១៩២សហវ.អថ.ហក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-កំណត់ហេតុប្រជុំស្តីពីការចរចាថ្លៃអង្ករ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ របស់គ.លក្រសួងការពារជាតិ

-លិខិតលេខ ០១៧/ស.ណ ២០១៧ ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៧ របស់ក្រសួងការពារជាតិ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងការពារជាតិ ក្នុងការប្រគល់កិច្ចសន្យាជូនក្រុមហ៊ុន **ម៉ែន សារុន អាហ័រណនីហ័រណ និងសំណង់** ដើម្បីផ្គត់ផ្គង់អង្ករបបកងទ័ពសម្រាប់ឆ្នាំ២០១៧ តាមតម្លៃ និងបរិមាណដូចខាងក្រោម :

**៣៣.០៤៧.០០០ គីឡូក្រាម x ២.៥៨៩រៀល = ៨៥.៥៥៨.៦៨៣.០០០ រៀល**

**(ប៉ែតសិបប្រាំប៊ីលាន ប្រាំរយហាសិបប្រាំបីលាន ប្រាំមួយរយប៉ែតសិបបីពាន់រៀលគត់)** ជាតម្លៃកិច្ចសន្យា ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រីមេត្តាជ្រាប និងមានវិធានការអនុវត្តបន្តឱ្យស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

ចម្លងជូន:

- អគ្គនាយកដ្ឋានពន្ធដារ
- អគ្គនាយកដ្ឋានថវិកា
- ក្រុមហ៊ុនម៉ែនសារុន អាហ័រណ នីហ័រណ និងសំណង់
- ឯកសារ-កាលប្បវត្តិ